00323118

C9/4/7

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

*គាំទនាមប្រជារាស្ត្រខ្មែរ និងតាំងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៣)

**ចំពោះមុខ:**
**ចៅក្រម ប្រាក់ គឹមសាន ប្រធាន**
**ចៅក្រម Rowan DOWNING**
**ចៅក្រម នីយ ថុល**
**ចៅក្រម Katinka LAHUIS**
**ចៅក្រម ហួត វុទ្ធី**

**កាលបរិច្ឆេទ:** **៤ ឧសភា ២០០៩**

---

សាធារណៈ (កាត់បន្ថយ)

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេច**
**អំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន**

---

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**

ជា លាង

Robert PETIT

យ៉េត ចរិយា

William SMITH

តាន់ សេណារ៉ុង

Anees AHMED

**<u>ជនត្រូវចោទ</u>**

នួន ជា

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

**<u>សហមេធាវីការពារក្តី</u>**

សុន អរុណ

Michiel PESTMAN

Victor KOPPE

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / MAY / 2009
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / MAY / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00323119

C9/4/7

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៣)

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នួន ជា ដែលបានដាក់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ("បណ្តឹងឧទ្ធរណ៍")។

## I. **ប្រវត្តិនីតិវិធី**

១. ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ("ដីកាសម្រេចបន្តការឃុំខ្លួន")។

២. នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ សហមេធាវីការពារជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ សហមេធាវីការពារជនត្រូវចោទបានដាក់សារណាបណ្តឹងឧទ្ធរណ៍។

៣. នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ នោះ។ នៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានលើកឡើងថា "ការសម្រេចអំពីបណ្តឹងនេះគួរតែធ្វើដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ"[1]។

៤. នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានផ្តល់យោបល់ជូនដល់អង្គបុរេជំនុំជម្រះថាពុំចាំបាច់មានសវនាការដេញដោលនោះទេ។

៥. នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨ បន្ទាប់ពីបានពិចារណាទស្សនៈរបស់សហព្រះរាជអាជ្ញា និងសហមេធាវីការពារជនត្រូវចោទ ("ភាគី")រួចមក អង្គបុរេជំនុំជម្រះបានសម្រេចថា បណ្តឹងឧទ្ធរណ៍នឹងត្រូវសម្រេចដោយផ្អែកលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។ មាត្រា៨.៥ នៃសេចក្តីណែនាំអនុវត្តចំពោះការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក បានអនុញ្ញាតឲ្យជនត្រូវចោទ

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨, C9/4/2 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា"), កថាខណ្ឌទី៣។

ដាក់ចម្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេល (៥)ថ្ងៃ ចាប់តាំងពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។ សហមេធាវីការពារជនត្រូវចោទមិនបានដាក់ចម្លើយតបនោះទេ។

៦. បន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍ភ្លាម អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿងក្តីដែលត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ។ ដើម្បីជាប្រយោជន៍ដល់ការពិចារណាលើបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះបានពិនិត្យឯកសារទាំងឡាយនៅក្នុងសំណុំរឿងព្រមទាំងភស្តុតាងទាំងអស់ ដែលត្រូវបានដាក់បន្ថែម រហូតដល់កាលបរិច្ឆេទដែលជនត្រូវចោទត្រូវបានអនុញ្ញាតឲ្យដាក់ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ហើយក៏ជាថ្ងៃចុងក្រោយដែលភាគីនានាអាចផ្តល់មតិយោបល់នានា ឬក៏អាចដាក់ភស្តុតាង ដើម្បីការពារផលប្រយោជន៍របស់ខ្លួនដែរ។

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៧. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា។ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ សហមេធាវីកាពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍។ សារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ និងធ្វើឡើងទៅតាមពេលវេលាកំណត់នៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងអ.វ.ត.ក (“វិធាន”)។

៨. សហមេធាវីការពារក្តីជនត្រូវចោទបានលើកឡើងថា អង្គបុរេជំនុំជម្រះមានយុត្តាធិការក្នុងការធ្វើសវនាការលើបណ្តឹងឧទ្ធរណ៍នេះ។ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូនអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា អនុលោមតាមវិធាន ៧៣, ៧៤ និង៧៥ នៃវិធានផ្ទៃក្នុង។ សហមេធាវីការពារក្តីបានស្នើសុំអង្គបុរេជំនុំជម្រះឲ្យ “ចាត់ទុកជាមោឃៈ នូវដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននោះ និងដោះ

លែងលោក នួន [ជា] ដោយមានលក្ខខណ្ឌនានាដែលបានលើកឡើងរួចមកហើយ នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន”[2]។

៩. នៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាមិនបានបញ្ចេញយោបល់ចំៗលើបញ្ហានានា ដែលពាក់ព័ន្ធនឹងយុត្តាធិការនោះទេ។

១០. វិធាន ៧៣ នៃវិធានផ្ទៃក្នុងបានចែងថា:

**“វិធាន ៧៣: យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ**
បន្ថែមពីលើអំណាចវិនិច្ឆ័យសេចក្តីលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬរវាងសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលត្រូវមានសមត្ថកិច្ចដើម្បីពិនិត្យលើ:
ក) បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងទៅនឹងសេចក្តីសម្រេច របស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធាន ៧៤ [...]”

១១. វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង បានចែងបន្ថែមទៀតថា:

**“វិធាន ៧៤: មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ**
៣. ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើប អង្កេតដូចខាងក្រោម:
[...]
ច. ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ។
[...]

១២. វិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង:

---

[2] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨, C9/4/1 (“សារណាលើបណ្តឹងឧទ្ធរណ៍”) កថាខណ្ឌទី២២។

00323122

C9/417



**"វិធាន ៦៣: ការឃុំខ្លួនបណ្តោះអាសន្ន**

៧. ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវមានសម្អាងហេតុ ចំពោះការពន្យារពេលនៃការបន្តឃុំខ្លួនបណ្តោះអាសន្ន។ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើបានតែក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ ហើយត្រូវផ្តល់រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីទុកពេលឲ្យប្តឹងតវ៉ាទៅសហចៅក្រមស៊ើបអង្កេត។ ទោះជាយ៉ាងណាក៏ដោយ ការពន្យារពេលមិនត្រូវឲ្យលើសពី ២ (ពីរ) ដងបានឡើយ។ ដីកាសម្រេចនេះបើកផ្លូវប្តឹងឧទ្ធរណ៍។

[...]"

១៣. បន្ទាប់ពីបានអានវិធាននានា នៃវិធានផ្ទៃក្នុងដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធានទាំងនេះបានផ្តល់ដល់អង្គបុរេជំនុំជម្រះនូវយុត្តាធិការសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

## III. **វិសាលភាពនៃការពិនិត្យ**

១៤. អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យថាតើ នៅមានហេតុផល ដែលត្រូវបានរកឃើញ និងអាចជឿបានថាជនត្រូវចោទ បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានលើកឡើងយ៉ាងជាក់លាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែរឬទេ ទោះបីជាជនត្រូវចោទមិនបានជំទាស់ទៅលើបញ្ហានេះក៏ដោយ។ អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចពិនិត្យមើល ថាតើសហចៅក្រមស៊ើបអង្កេតអាចធ្វើសេចក្តីសន្និដ្ឋានដូច្នេះដោយឈរលើមូលដ្ឋាននៃកិច្ចស៊ើបសួរដែលនៅតែបន្តបានដែរឬទេ ហើយអង្គបុរេជំនុំជម្រះត្រូវពិនិត្យសំណុំរឿង រហូតមកដល់នឹងកាលបរិច្ឆេទដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី៦ នៃសេចក្តីសម្រេចនេះ ដើម្បីពិនិត្យថាតើ ហេតុផលមានសំអាងនោះនៅតែមានអត្ថិភាពឬយ៉ាងណា។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការធ្វើបែបនេះគឺជាការត្រឹមត្រូវ ពីព្រោះថា ក្នុងអំឡុងពេលនៃការស៊ើបអង្កេតដែលនៅតែបន្ត សហចៅក្រមស៊ើបអង្កេតធ្វើការអង្កេតទាំងលើភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដែលត្រូវបានដាក់បន្ថែមចូលក្នុងសំណុំរឿង។

១៥. អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យបន្ថែមទៀត ទៅលើបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ហើយនៅទីបំផុត អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណា ថាតើសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនសមហេតុសមផលដែរឬទេ។

## IV. **បណ្តឹងឧទ្ធរណ៍**

១៦. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានសន្និដ្ឋានថាៈ

១) "ការបន្តថិរវេលាឃុំខ្លួនលោក នួន ជា មិនមានយុត្តិកម្មទាំងអង្គហេតុ ទាំងអង្គច្បាប់។
២) ដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នមានការខ្វះចន្លោះផ្នែកនីតិវិធី និង
៣) ការដោះលែងបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌគឺជាការត្រឹមត្រូវក្នុងកាលៈទេសៈនេះ"[3]។

ដោយឈរលើមូលដ្ឋានដូចខាងក្រោមៈ

(១) "មេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាលើសារណានៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន នៅត្រង់កថាខណ្ឌទី២៤ ដល់ទី២៨ និងកថាខណ្ឌទី៨ ដល់ទី៩ នៃការជំទាស់តវ៉ាទៅនឹងការបន្តថិរវេលានៃការឃុំខ្លួន។ វាជាការរំលឹកឡើងវិញថា យុត្តិសាស្ត្រសិទ្ធិមនុស្សដែលអាចអនុវត្តបាន បានរកឃើញជារឿយៗថា ហានិភ័យលើកដំបូង ដែលធ្វើជាយុត្តិកម្មសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន (ឧទាហរណ៍ ហានិភ័យដែលមានចែង នៅក្នុងវិធាន ៦៣(៣)(ខ) បានថយចុះជាបណ្តើរៗទៅតាមពេលវេលា។ តាមពិត ការពឹងអាស្រ័យទៅលើករណីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ហៅថា "ECHR") អង្គជំនុំជម្រះនេះបានធ្វើការកត់សម្គាល់ កាលពីពេលថ្មីៗនេះថា "ខណៈពេលដែលហានិភ័យជាទូទៅត្រូវបានបង្កើត [...] "ប្រហែលអាច" ទទួលយកមកធ្វើជាមូលដ្ឋានសម្រាប់ការឃុំខ្លួននៅដំណាក់កាលដំបូង នៃដំណើរការនីតិវិធី ការកន្លង ផុត

[3] សារណាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១។

00323124

C9/4/7



នៃពេលវេលា តម្រូវឱ្យមានការបង្ហាញកត្តាផ្សេងៗទៀត ដែលអាចបញ្ជាក់ថា ហានិភ័យនេះពិតជានៅមានអត្ថិភាពមែន"[4]។

"អត្ថិភាពនៃមូលហេតុដែលនាំឱ្យជឿជាក់យ៉ាងច្បាស់តែម្យ៉ាងថា លោក នួន ជា បានប្រព្រឹត្ត ឧក្រិដ្ឋកម្មជាច្រើននោះ គឺមិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នោះទេ។ ក្នុងន័យនេះហើយ មេធាវីការពារក្តីស្នើសុំឱ្យដាក់បញ្ចូលសារណាដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន [កថាខណ្ឌទី៤៤-៥៣] និងស្នើសុំឱ្យលើកយកសារណាទាំងនេះមកពិចារណាសារជាថ្មី។ យោងតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបដែលបានលើកឡើងខាងលើ ជាពិសេសទឡ្ហីករណ៍ដែលទាក់ទងទៅនឹងវិធានផ្ទៃក្នុងទី៦៣(៣)(ខ)(i) និង(ii) កាន់តែធ្វើឱ្យមានទម្ងន់ថែមទៀត ដោយ ក.ស.ច.ស បានចំណាយពេលពេញមួយឆ្នាំក្នុងការស៊ើបអង្កេតរបស់ខ្លួន។ ទោះបីជាមានការទទួលយកអំណះអំណាងរបស់ក.ស.ច.ស ជាទូទៅហើយក៏ដោយ ក៏ ក.ស.ច.ស. ខកខានមិនបានពន្យល់អំពីរបៀបដែលថា ហានិភ័យ*ដែលត្រូវបានបង្កើតជាលក្ខណៈទូទៅ* សម្រាប់ធ្វើយុត្តិកម្មចំពោះការឃុំខ្លួនលោក នួន ជា លើកដំបូងនោះ ត្រូវបានគាំទ្រដោយ*ភស្តុតាងជាក់ស្តែង* តាមការតម្រូវនោះទេ"[5]។

(២) "អនុលោមទៅតាមវិធានផ្ទៃក្នុង [សូមមើលវិធាន ៦៣(២)(ក)] ដីកាឃុំខ្លួនបណ្តោះអាសន្នត្រូវតែ "បញ្ជាក់អំពីអង្គហេតុនិងអង្គច្បាប់សម្រាប់ជាមូលដ្ឋាននៃការឃុំខ្លួន"។ រាល់ដីកាបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ជាក់ពីមូលហេតុដូចគ្នា [សូមមើលវិធាន ៦៣ (៧)] ហើយគ្រាន់តែនិយាយយោងចំពោះបញ្ញត្តិច្បាប់ប៉ុណ្ណោះគឺមិនគ្រប់គ្រាន់ទេ។ សំខាន់ជាងនេះទៅទៀត ការវិភាគអរូបីឬមានលក្ខណៈទូទៅគឺជាការវិភាគដែលមិនគ្រប់គ្រាន់។ ផ្ទុយទៅវិញ តុលាការដែលមានសមត្ថកិច្ចលើករណីនេះ ត្រូវតែ "កត់ត្រារាល់អំណះអំណាងទាំងអស់ដែលគាំទ្រដល់ការដោះលែង និងអំណះអំណាងទាំងឡាយដែលប្រឆាំងនឹងការដោះលែង នៅក្នុងដីកាសម្រេចមានមូលហេតុ"។ មូលហេតុមានពីរៈ ទី១ គឺដើម្បីអនុញ្ញាតឱ្យជនត្រូវចោទប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាព និងទី២ ដើម្បីរក្សាទំនុកចិត្តរបស់សាធារណជនទៅលើដំណើរការស្វែងរកយុត្តិធម៌"[6]។

---

[4] សារណាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១០។

[5] សារណាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១៧។

[6] សារណាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១១។

(៣) "ច្បាប់សិទ្ធិមនុស្សទទួលស្គាល់ "សិទ្ធិ*បឋម* ដែលត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងពេលរង់ចាំសវនាការ"។ ដោយសារការឃុំខ្លួនបុគ្គលម្នាក់ដែលត្រូវបានគេសន្មតទុកជាមុនថាគ្មានទោស គឺជាវិធានការធ្ងន់ធ្ងរនោះ ការឃុំខ្លួននេះអាចមានយុត្តិកម្មបាន តែក្នុងករណីដែលជម្រើសវិធានការមានលក្ខណៈមិនសូវធ្ងន់ធ្ងរ ត្រូវបានយកមកពិចារណា និងបានរកឃើញថាមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានាការពារដល់ផលប្រយោជន៍បុគ្គល ឬផលប្រយោជន៍សាធារណៈបានតែប៉ុណ្ណោះ។ ប្រសិនបើការសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបានបដិសេធនោះ ជនត្រូវចោទមានសិទ្ធិ "ឱ្យព្រះរាជអាជ្ញានិងតុលាការចាត់ការលើរឿងក្តីរបស់ខ្លួនជាអាទិភាព"[7]។

១៧. សហមេធាវីការពារក្តីបានសន្និដ្ឋានថា:

"អាស្រ័យដោយមូលហេតុដូចបានលើកឡើងខាងលើ មេធាវីការពារក្តីសំណូមពរឱ្យអង្គបុរេជំនុំជម្រះលុបចោលដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងដោះលែង លោក នួន [ជា] ដោយមានលក្ខខណ្ឌនានាដែលបានលើកឡើងរួចមកហើយ នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ជម្រើសម្យ៉ាងទៀត អង្គបុរេជំនុំជម្រះគួររៀបចំចាត់ចែងជាចាំបាច់សម្រាប់ការបញ្ជូនលោក នួន [ជា] ទៅកាន់មន្ទីរពេទ្យណាមួយនៅកណ្តាលទីក្រុងភ្នំពេញ ដែលបានព្រមព្រៀងគ្នារួចហើយ។ ជាទីបញ្ចប់និងក្នុងស្ថានភាពណាក៏ដោយ អង្គបុរេជំនុំជម្រះគួរណែនាំសហចៅក្រមស៊ើបអង្កេតឱ្យរៀបចំពង្រាងរបស់ខ្លួន ដោយអនុលោមទៅតាមវិធាន ទាំងឡាយដែលនៅជាធរមាន និងយុត្តិសាស្ត្រដែលពាក់ព័ន្ធ"[8]។

---

[7] សារណាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១៤។

[8] សារណាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី២២។

## V. ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍

១៨. សហព្រះរាជអាជ្ញាបានស្នើសុំអង្គបុរេជំនុំជម្រះ ឲ្យបដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ ដោយឈរលើមូលដ្ឋានដូចខាងក្រោម៖

"(ក) ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានចង្អុលបង្ហាញពីការប្រែប្រួលស្ថានភាព ចាប់តាំងពីគាត់ត្រូវបានឃុំខ្លួន ដោយសហចៅក្រមស៊ើបអង្កេតដំបូងកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ("ដីកាឃុំខ្លួន")[9] និងចាប់តាំងពីមានការបញ្ជាក់ពីការឃុំខ្លួននោះ ដោយអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួន")"[10]។

(ខ) លក្ខខណ្ឌខុសៗគ្នាទាំងប្រាំដែលតម្រូវឲ្យមានការឃុំខ្លួនជាចាំបាច់ ស្របតាមវិធាន ៦៣(៣)(ខ) នៅតែត្រូវបានបំពេញ ជាលក្ខខណ្ឌរួមគ្នាក្តី ឬលក្ខខណ្ឌដាច់ដោយឡែកនីមួយៗក្តី។ ជាក់ស្តែង ការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍នៅតែជាវិធានការចាំបាច់មួយ: (១) ដើម្បីរាំងដើមបណ្តឹងឧទ្ធរណ៍កុំឲ្យគាបសង្កត់សាក្សីឬជនរងគ្រោះ (២) ដើម្បីរក្សាភស្តុតាងឬដើម្បីការពារកុំឲ្យមានការបំផ្លាញភស្តុតាង (៣) ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងពេលដំណើរការនីតិវិធី (៤) ដើម្បីការពារ សន្តិសុខរបស់គាត់ និង (៥) ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

(គ) ការឃុំខ្លួននៅក្នុងផ្ទះមិនត្រូវបានអនុញ្ញាតឡើយ ដោយសារតែមន្ទីរឃុំឃាំងរបស់ អ.វ.ត.កមានបំពាក់សម្ភារៈសមស្រប សម្រាប់ការសង្គ្រោះបន្ទាន់ ហើយទោះជាស្ថិតនៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ស្ថានភាពសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ មិនអាចធ្វើយុត្តិកម្មសម្រាប់ការកែប្រែលក្ខខណ្ឌនៃការឃុំខ្លួនរបស់គាត់បានឡើយ"[11]។

---

[9] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, C11/1។

[10] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២008, C11/54។

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌទី២។

សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

00323127

C9/4/7

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៣)

## VI. ដីការបស់សហចៅក្រមស៊ើបអង្កេត

១៩. ដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ នួន ជា ("ដីកាស្ដីពីការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន") ចុះថ្ងៃ ទី១៦ ខែកញ្ញា ឆ្នាំ២០០៨ បានលើកឡើងថា:

> "តាមរយៈដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មានហេតុផលសមស្របដែលនាំឲ្យជឿបានថា ជនត្រូវចោទ នួន ជា បានប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ថា ភស្តុតាង ដែលមាននៅក្នុងសំណុំរឿងក្នុងដំណាក់កាលនោះ (ជាពិសេសសូមមើលកថាខណ្ឌទី៤៣-៥៨) មានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញអំពីការជឿជាក់នេះ។ ក្រោយមក ការស៊ើបសួរលើជនត្រូវចោទក៏នៅតែបន្ត។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់លើភស្តុតាងបន្ថែមនានា ដែលប្រមូលបាន និងបានដាក់បញ្ចូលភស្តុតាងទាំងនោះទៅក្នុងសំណុំរឿង ជាពិសេសរួមមាន ចម្លើយបន្ថែមចំនួន ២៣ របស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងបរិបទ និងដំណើរការនៃមន្ទីរ ស-២១ ក៏ដូចជាតួនាទីរបស់ជនត្រូវចោទ នួន ជា នៅក្នុងបញ្ហាទាំងនោះផងដែរ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតយល់ថា លក្ខខណ្ឌ ដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុងនៅតែត្រូវបានបំពេញ"[12]។

២០. ដីកាស្ដីពីការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ក៏បានលើកឡើងផងដែរថា សហចៅក្រមស៊ើបអង្កេតបានពិចារណាបន្ថែមថា "លក្ខខណ្ឌនានាដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ក៏នៅតែត្រូវបានបំពេញ ហើយថាសម្អាងហេតុនៅក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ នៅតែមានសុពលភាពដដែល"។ សហចៅ

---

[12] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨, C9/3 ("ដីកាសម្រេចអំពីការបន្តថិរវេលា"), ទំព័រទី២។

ក្រមស៊ើបអង្កេតបានសម្រេច "ឲ្យមានការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំបន្ថែមទៀត [...]"[13]។

## VII. មូលដ្ឋានដែលត្រូវបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេត ស្តីអំពីហេតុផលដែលមានសំអាងហេតុច្បាស់លាស់

២១. អនុលោមតាមវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចផ្តល់នូវមូលហេតុសម្រាប់ចេញដីកាសម្រេចបន្តថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីបណ្តឹងឧទ្ធរណ៍របស់ជន ត្រូវចោទ នួន ជា ពាក់ព័ន្ធនឹងសំណើសុំមោឃភាព អង្គបុរេជំនុំជម្រះយល់ឃើញថា "សេចក្តីសម្រេចទាំងអស់របស់តុលាការ តម្រូវឲ្យផ្តល់សំអាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ"[14]។ ហេតុដូច្នេះហើយ ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវតែលើកឡើងអំពីហេតុផលទាំងឡាយនៃការបន្តថិរវេលានៃការឃុំខ្លួន។

២២. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើទៅបាន នៅពេលណាដែលលក្ខខណ្ឌនានាដែលបានចែងនៅក្នុងវិធាន ៦៣(ក) នៅតែត្រូវបានបំពេញ ដោយមិនគិតពីការកន្លងផុតទៅនៃពេលវេលា និងមិនពាក់ព័ន្ធទៅនឹងលទ្ធផលនៃការស៊ើបអង្កេតនោះទេ។

២៣. សហចៅក្រមស៊ើបអង្កេតបានបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដោយរក្សាដូចដើមនូវហេតុផលនានានៃការឃុំខ្លួន ដែលមាននៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះពីមុន និងដោយបានធ្វើការពិចារណាទៅលើភស្តុតាងដាក់បន្ទុកថ្មីៗមួយចំនួន។ សហចៅក្រមស៊ើបអង្កេតបាននឹងកំពុងប្រមូលភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ក្នុងកិច្ចដំណើរការស៊ើបអង្កេតរបស់ខ្លួន។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមិនបានរក

---

[13] ដីកាសម្រេចអំពីការបន្តថិរវេលា, ទំព័រទី២។

[14] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព,ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨, D55/I/8, កថាខណ្ឌទី២១។

ឃើញភស្តុតាងដោះបន្ទុកឱ្យបានគ្រប់គ្រាន់ ដើម្បីបង្ហាញនៅក្នុងដីការបស់ខ្លួននោះឡើយ។ ដោយពិចារណាលើបញ្ហានេះ និងបញ្ហាដែលថាសហមេធាវីការពារក្តីជនត្រូវចោទមិនបានបង្ហាញភស្តុតាងដោះបន្ទុក នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានស្នើសុំ ដើម្បីបង្ហាញពីការប្រឆាំងជំទាស់ទៅនឹងការសម្រេចបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ននោះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេត បានបំពេញកាតព្វកិច្ចក្នុងការផ្តល់ហេតុផលនៃការសម្រេចបន្តថិរវេលានៃការឃុំខ្លួននេះយ៉ាងត្រឹមត្រូវ ហើយបទដ្ឋានដ៏ត្រឹមត្រូវក៏ត្រូវបានប្រើប្រាស់ផងដែរ។

**មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ នាពេលបច្ចុប្បន្ន ថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬច្រើន ដូចដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)**

២៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ថិរវេលាដែលកំណត់សម្រាប់ការបន្តការឃុំខ្លួន គឺជាសេចក្តីពេញចិត្តរបស់អ្នកសង្កេតអព្យាក្រឹត ដែលថា ជនត្រូវចោទមានការទទួលខុសត្រូវ ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដូចដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ នេះគឺជាបទដ្ឋានដែលត្រូវបានអង្គបុរេជំនុំជម្រះបានអនុវត្តតាមកន្លងមក[15]។ សហមេធាវីការពារក្តីជនត្រូវចោទមិនប្រឆាំងជំទាស់ទៅនឹងអត្ថិភាពនៃ ហេតុផលមានសំអាងច្បាស់លាស់ នានាដែលនាំឱ្យជឿបានថា ជនត្រូវចោទមានការទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងឡាយដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិនានានៅមន្ទីរ ស-២១ នោះទេ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនឹងមិនពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង មុនពេលសារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូននោះឡើយ។ អង្គបុរេជំនុំជម្រះ យល់ឃើញថា ចម្លើយថ្មីៗ ដែលបានផ្តល់ដោយ [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច] ចុះថ្ងៃទី១៩ និងទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ បានបន្ថែមចូលទៅលើភស្តុតាងដែលមានស្រាប់ដែលគាំទ្រដល់ហេតុផលមានសំអាងដែលនាំឱ្យជឿបានថា ជនត្រូវចោទបានចូលរួមចំណែក

---

[15] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ នួន ជា បណ្តោះអាសន្ន, កថាខណ្ឌ១៩៦; សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, C22/I/74, កថាខណ្ឌទី៧១; និង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង ធីរិទ្ធ បណ្តោះអាសន្ន, ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨, កថាខណ្ឌទី២១។

រួចទៅហើយនៅក្នុងរចនាសម្ព័ន្ធ បញ្ជាការជាន់ខ្ពស់ខ្មែរក្រហមដែលទទួលបន្ទុកបង្កើត និង អនុវត្តគោលនយោបាយនៃរបបនោះ[16]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ពុំមានភស្តុតាង ដោះបន្ទុកណាមួយត្រូវបានដាក់ចូលនៅក្នុងសំណុំរឿង នៅចន្លោះពេលនៃការចេញដីកាឃុំខ្លួន បណ្តោះអាសន្ន និងពេលនៃការចេញដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នោះទេ។

២៥. មានចម្លើយថ្មីៗ ដែលជាភស្តុតាងពាក់ព័ន្ធនឹងតួនាទីរបស់ជនត្រូវចោទដែលត្រូវបានចោទប្រកាន់ ដែលទាក់ទងនឹងសកម្មភាព ដែលពាក់ព័ន្ធនឹងមន្ទីរស-២១ [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច] ។

២៦. ចម្លើយមួយនៅក្នុងចំណោមចម្លើយទាំងនេះ[17] បាននិយាយអំពីអំពើទារុណកម្មដ៏ធ្ងន់ធ្ងរមកលើអ្នក ទោសកម្រិតធ្ងន់នៅក្នុង[ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច]ដែលជាកន្លែងឃុំឃាំងមួយដែរ។ នៅក្នុង [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច] មានអគារតែមួយគត់សម្រាប់អ្នកទោសកម្រិតធ្ងន់ដែលគេបាន បិទយ៉ាងជិត ពុំមានបង្អួច និងមានតែទ្វារចូលមួយប៉ុណ្ណោះ។ នៅពេលយប់ ទ្វារត្រូវគេចាក់សោរ និងត្រូវគេយាមល្បាតជាប់ជានិច្ច។ អ្នកទោសត្រូវបានអនុញ្ញាតឱ្យចេញទៅខាងក្រៅដោយជើងជាប់ ខ្នោះ តែនៅពេលដែលត្រូវធ្វើការងារតែប៉ុណ្ណោះ។ អាហារប្រចាំថ្ងៃរបស់ពួកគាត់គឺបបររាវ ដែលត្រូវបានចម្អិន នៅក្នុងខ្ទះធំៗដោយដាក់អង្ករតែ៤កំប៉ុង សម្រាប់មនុស្ស៣០នាក់ហូប។ សាក្សីម្នាក់ ក្នុងចំណោមសាក្សីនានាបានឃើញវិធី ដែលឈ្លបវាយប្រជាជនចំនួន៥គ្រួសារ ដោយប្រើដំបង និងបានសម្លាប់ពួកគេ[ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច]នៅក្នុងព្រៃ[18]។ ជនត្រូវចោទក៏ត្រូវបាន ចោទថាបានរៀបចំការប្រជុំនានា ដើម្បីរៀបចំផែនការបោសសម្អាតខ្មាំងសត្រូវផ្ទៃក្នុង ដូចជាទាហាន និងកងកុម្ម៉ង់ដូដែលទាក់ទិននឹងសម័យសង្គមរាស្ត្រនិយម និងសម័យលន់ នល់ ឬក៏ត្រូវបានចោទ ប្រកាន់ពីការតស៊ូប្រឆាំងនឹងរបបខ្មែរក្រហមជាទូទៅ[19]។

---

[16] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨, D117, និង ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨, D118។

[17] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៨, D125/162 ("ការស្តាប់ចម្លើយ សាក្សី [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច]"), ទំព័រទី៥។

[18] ការស្តាប់ចម្លើយសាក្សី [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ទំព័រទី៥។

[19] ការស្តាប់ចម្លើយសាក្សី [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ទំព័រទី២ និងទី៣។

00323131



២៧. ចម្លើយមួយទៀតបានបង្ហាញថាជនត្រូវចោទគឺជាអ្នកដែលរៀបចំផែនការនានា និងជាញឹកញាប់បានជួបជាមួយមេបញ្ជាការតំបន់ មេបញ្ជាការស្រុក និងមេបញ្ជាការភូមិភាគ ដែលបានអនុវត្តតាមបញ្ជារបស់គាត់ ដែលកំណត់ឱ្យបោសសម្អាត ចាប់ខ្លួន និងសម្លាប់ប្រជាជន ដោយសារតែពួកគេគ្រាន់តែពាក់ព័ន្ធនឹងប្រជាជនដែលមកពីប្រទេសវៀតណាម ឬក៏ពីព្រោះពួកគេបានស្នើសុំឱ្យមានការចរចារជាមួយប្រទេសវៀតណាម ក្នុងគោលបំណងដើម្បីចៀសវាងការប្រយុទ្ធគ្នាប៉ុណ្ណោះ[20]។

២៨. ចម្លើយទាំងពីរនេះបានចោទថា ចៅហ្វាយស្រុកនិងប្រធានតំបន់ត្រូវបានជនត្រូវចោទបញ្ជា ដោយផ្ទាល់ឱ្យទៅរៀនសូត្រនៅភ្នំពេញ និងក្រោយមកត្រូវបានគេប្រទះឃើញស្លាប់ យ៉ាងសាហាវព្រៃផ្សៃ ឬបានបាត់ខ្លួនជារៀងរហូត[21]។

២៩. យោងតាមសក្ខីកម្មថ្មីៗរបស់សាក្សីនានា ជនត្រូវចោទមានតួនាទីដាក់បទបញ្ជាឱ្យបុគ្គលិក បន្ថែមពីលើបទបញ្ជានៅមន្ទីរស-២១ រីឯលទ្ធផលនៃការអនុវត្តតាមបទបញ្ជាបែបនោះ គឺការបោសសម្អាត ការចាប់ខ្លួន ការសម្លាប់ និងការធ្វើបាបអ្នកទោស។ នាពេលបច្ចុប្បន្ន រឿងនេះមានការពេញចិត្តដល់អ្នកសង្កេតអញ្ញាក្រឹត ដែលជនត្រូវចោទមានការទទួលខុសត្រូវ ឬក៏បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានចោទប្រកាន់ [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច]។

**ការពិចារណាលើមូលដ្ឋានដែលធ្វើឱ្យការឃុំខ្លួនបណ្ដោះអាសន្នក្លាយជាវិធានការដ៏ចាំបាច់ (វិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង)**

៣០. ជនត្រូវចោទមិនបានបង្ហាញអង្គហេតុ ឬកាលៈទេសៈថ្មីៗដែលបង្ហាញថា លក្ខខណ្ឌនានា នៃវិធាន ៦៣(៣)(ខ) មានការប្រែប្រួល ដើម្បីធ្វើឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនេះជឿជាក់ថា ការឃុំខ្លួនលែងជាការចាំបាច់ទៀតហើយនាពេលបច្ចុប្បន្ននេះ។ នៅក្នុងដីកាសម្រេចបន្តថិរវេលា

[20] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨, D125/160 ("ការស្ដាប់ចម្លើយសាក្សី [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច]"), ទំព័រទី៣ ទី៤ និងទី៧។

[21] ការស្ដាប់ចម្លើយសាក្សី[ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច] និង D125/160។

00323132

C9/417



នៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអំពីហេតុផល នៃហានិភ័យដែលនាំឱ្យមានការឃុំខ្លួនបឋម នៅមានអត្ថិភាពនោះទេ។ ពាក់ព័ន្ធនឹងបញ្ហានេះ ដីការបស់សហចៅក្រមស៊ើបអង្កេតខ្វះការបង្ហាញហេតុផលឱ្យបានគ្រប់គ្រាន់[22]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះត្រូវធ្វើការពិចារណាដោយខ្លួនឯងផ្ទាល់ថាតើលក្ខខណ្ឌនានានៃវិធាន ៦៣(៣)(ខ) នៅតែយកមកអនុវត្តបានដែរឬទេ។

**វិធាន ៦៣(៣)(ខ): (i) ដើម្បី "រារាំងជនត្រូវចោទកុំឱ្យដាក់ការគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ" និង (ii) ដើម្បី "ថែរក្សាភស្តុតាង ឬការពារមិនឱ្យមានការបំផ្លាញភស្តុតាង"**

៣១. អង្គបុរេជំនុំជម្រះយល់ឃើញថា ពេលវេលាដែលកន្លងផុតទៅមិនបានធ្វើឱ្យហានិភ័យនៃការគាបសង្កត់លើសាក្សី ឬការត្រូវរ៉ូវគ្នាមានការថយចុះឡើយ។ ផ្ទុយទៅវិញ ហានិភ័យនេះកាន់តែមានគ្រោះថ្នាក់ថែមទៀតនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ នៅពេលដែលមានកំណត់ហេតុចេះតែច្រើនឡើងៗ នៅក្នុងសំណុំរឿង។ ការយល់ដឹងរបស់ជនត្រូវចោទអំពីអត្តសញ្ញាណ និងព័ត៌មានពិស្តាររបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី មានការកើនឡើងប្រៀបធៀបទៅនឹងពេលដែលជនត្រូវចោទត្រូវបានឃុំខ្លួនដំបូង។ បញ្ហានេះបង្កើននូវលទ្ធភាពដែលជនត្រូវចោទអាចធ្វើការគាបសង្កត់លើសាក្សីដែលត្រូវបានសួរយកចម្លើយ និងអាចត្រូវបានសួរយកចម្លើយសារជាថ្មី និងសាក្សីទាំងឡាយណា ដែលមិនទាន់ត្រូវបានសួរយកចម្លើយនៅឡើយ។ ភវនីយភាពនេះគឺផ្អែកទៅលើអត្តចរិតរបស់ជនត្រូវចោទកាលពីអតីតកាល។ ដូច្នេះ បន្ថែមលើឧទាហរណ៍ដែលលើកឡើងដោយអង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នពីមុនរបស់ខ្លួន[23] មានភស្តុតាងថ្មីនៅក្នុងសំណុំរឿង ដែលផ្អែកតាមភស្តុតាងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ជនត្រូវចោទបានគាបសង្កត់លើ [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច] ដោយបានគម្រាមកំហែងគាត់ ក្នុងគោលបំណង

---

[22] សាលដីការលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, កថាខណ្ឌទី២១។

[23] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ នួន ជា បណ្តោះអាសន្ន, កថាខណ្ឌទី៦១។

00323133





ដើម្បីឱ្យគាត់ដកចម្លើយសារភាពដែលទាក់ទងនឹងការឆ្លើយដាក់ "សមាជិកថ្នាក់លើ"[24]។ ភស្តុតាងផ្សេងទៀត ដែលត្រូវបានរកឃើញនៅក្នុងសំណុំរឿងបង្ហាញថា សាក្សីនៅតែមានការភ័យខ្លាចចំពោះការសម្លុត គម្រាមកំហែងពិតមែន[25]។

៣២. អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ ដើម្បីរារាំងជនត្រូវចោទកុំឱ្យដាក់ការគាបសង្កត់លើសាក្សី ឬក៏បំផ្លាញភស្តុតាង។

**មូលដ្ឋានទី៣ នៅក្នុងវិធាន ៦៣(៣)(ខ): (iii) ដើម្បី "ធានានូវវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី"**

៣៣. ពាក់ព័ន្ធនឹងស្ថានទម្ងន់នៃការចោទប្រកាន់ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ជនត្រូវចោទអាចប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពី៥ឆ្នាំ ទៅមួយជីវិត ក្នុងករណីដែលរកឃើញថាគាត់មានពិរុទ្ធ។ ពុំមានឯកសារឬភស្តុតាងអ្វីមួយដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងចាប់តាំងពីការចេញសេចក្តីសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នពីមុនរបស់អង្គជំនុំជម្រះ[26] នាំឱ្យមានការសន្និដ្ឋានថាមានការប្រែប្រួលកាលៈទេសៈនោះទេ។ លើសពីនេះទៅទៀត ភស្តុតាងថ្មី ដែលត្រូវបានពិចារណាខាងលើ បានបន្ថែមនូវទឡ្ហីករណ៍គាំទ្រដល់ទំនាក់ទំនងគ្នារវាងអង្គហេតុដែលត្រូវបានចោទប្រកាន់ និងជនត្រូវចោទ ដែលជាការដាក់បន្ទុកបន្ថែមលើរូបគាត់។

៣៤. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

**មូលដ្ឋានទី៤ នៅក្នុងវិធាន ៦៣(៣)(ខ): (iv) ដើម្បី "ការពារសន្តិសុខជនត្រូវចោទ"**

---

[24] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយ[ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨, D119, ទំព័រទី៤ និងទី៥។

[25] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៨, D123/1 ទំព័រទី១២-១៤។

[26] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ នួន ជា បណ្តោះអាសន្ន។

៣៥. បន្ទាប់ពីបានផ្តល់នូវហេតុផលមានសំអាងដែលនាំឲ្យជឿថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់និងដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនានាដែល កាំង ហ្កេកអ៊ាវ បានទទួលនូវការចោទប្រកាន់រួចមក អង្គបុរេជំនុំជម្រះយល់ឃើញថា ការខឹងសម្បាដែលកើតចេញមកពីសាធារណជនប្រឆាំងនឹង កាំង ហ្កេអ៊ាវ នៅក្នុងអំឡុងពេលសវនាការលើកទី១ ក៏អាចជាការប៉ះទង្គិចទៅលើជនត្រូវចោទរូបនេះដែរ[27]។

៣៦. ពាក់ព័ន្ធនឹងការអះអាងរបស់សហមេធាវីការពារក្តីដែលថា ជនត្រូវចោទត្រូវបានធ្វើសមាហរណកម្មទៅក្នុងសង្គមកម្ពុជាដោយសន្តិភាពយ៉ាងពេញលេញ អស់រយៈពេលជិត១០ឆ្នាំមកហើយ ដែលនៅក្នុងអំឡុងពេលនេះពុំមានអំពើហឹង្សាណាមួយ ធ្វើឡើងប្រឆាំងនឹងសេរីភាពរបស់គាត់ ឬក៏អំពើសងសឹកណាមួយដែលត្រូវគេប៉ុនប៉ងធ្វើប្រឆាំងនឹងរូបគាត់នោះឡើយ អង្គបុរេជំនុំជម្រះសង្កេតឃើញថាភាពស្ងប់ស្ងាត់គ្មានការរំខានបែបនេះអាចដាក់បញ្ចូលទៅក្នុងបរិការណ៍នៃនិទណ្ឌភាព ដែលគ្របដណ្តប់រយៈពេលជិត៣០ឆ្នាំនេះ។ លើសពីនេះទៅទៀត ផ្ទះរបស់ជនត្រូវចោទត្រូវបានគេយាមរួចទៅហើយ[28]។ ភាពចាំបាច់នៃការយាមផ្ទះនេះ គឺជាការបង្ហាញដល់អង្គបុរេជំនុំជម្រះថា ពុំមានសមាហរណកម្មប្រកបដោយសន្តិភាពណាមួយ ដូចដែលសហេមធាវីការពារក្តីបានអះអាងនោះទេ ហើយជាការពិត ការយាមផ្ទះនេះបានបង្ហាញនូវភស្តុតាងថា ជនត្រូវចោទខ្លួនឯងផ្ទាល់បានភ័យខ្លាចចំពោះសុវត្ថិភាពរបស់ខ្លួន។

---

[27] Erika Kinetz និង យន់ សាមាន (Yun Samean), *The Cambodia Daily,* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧, "ឌុច ប្រឈមមុខនឹងចៅក្រមក្នុងសវនាការជាសាធារណៈលើកដំបូងរបស់ អ.វ.ត.ក" (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ឧបសម្ព័ន ក, ឯកសារភ្ជាប់ក២៤)។

[28] សូមមើលបទសម្ភាសន៍របស់ [ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួច], ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ (ERN 00000925-00000935); Don Pathan, *Associated Press,* ចុះផ្សាយថ្ងៃទី៩ ខែមករា ឆ្នាំ១៩៩៩, "អតីតមូលដ្ឋានរឹងមាំរបស់ខ្មែរក្រហមកំពុងក្លាយជាឋានសួគ៌ដ៏សុខសាន្តសម្រាប់មេដឹកនាំ (Former Khmer Rouge stronghold becoming safe haven for leaders)" (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ឧបសម្ព័ន្ធ ខ); *រស្មីកម្ពុជា,* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ឧបសម្ព័ន្ធ ខ)។

៣៧. អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ ដើម្បីការពារសុវត្ថិភាពរបស់ជនត្រូវចោទ។

**មូលដ្ឋានទី៥ នៅក្នុងវិធាន ៦៣(៣)(ខ): (v) ដើម្បី "រក្សាសណ្តាប់ធ្នាប់សាធារណៈ"**

៣៨. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីមិនបានលើកនូវទឡ្ហីករណ៍ដែលចង្អុលបង្ហាញអំពីការប្រែប្រួលកាលៈទេសៈណាមួយ ដើម្បីជជែកតវ៉ាចំពោះមូលដ្ឋាននៃការឃុំខ្លួននេះទេ។ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា "ពេលវេលាដែលកន្លងហួសទៅ មិនបានកាត់បន្ថយផលប៉ះពាល់ នៃរបបកម្ពុជាប្រជាធិបតេយ្យទៅលើសង្គមកម្ពុជាទេ"។ ដោយរំឭកឡើងវិញនូវទឡ្ហីករណ៍របស់អង្គជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចពីមុនអំពីការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា "ការបន្តឃុំខ្លួនគឺជាវិធានការចាំបាច់"[29]។

៣៩. អង្គបុរេជំនុំជម្រះយល់ឃើញថា ការពិចារណាទៅលើហេតុផលនៃមូលដ្ឋាននៃការឃុំខ្លួននេះ ក៏អាចយកមកប្រើសម្រាប់កាលៈទេសៈបច្ចុប្បន្ននេះដែរ។ ពេលវេលាដែលកន្លងហួសទៅមិនបានកាត់បន្ថយនូវផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យទៅលើសង្គមកម្ពុជាទេ។ គេជឿជាក់ថា ប្រជាជនកម្ពុជាមួយចំនួនដែលធ្លាប់បានរស់នៅក្នុងរយៈកាលនោះ គិតពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅតែមានការឈឺចាប់ដោយសារជំងឺបាក់ស្បាត។ អ្នកជំនាញនានាបានលើកឡើងថា ការចាប់ផ្តើមដំណើរការតុលាការ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ "អាចចោទជាហានិភ័យថ្មីមួយចំពោះសង្គមកម្ពុជា"។ តុលាការនេះក៏អាច "នាំឲ្យកើតមានឡើងវិញនូវក្តីព្រួយបារម្ភនិងផលវិបាកសង្គមជាអវិជ្ជមាននានាផងដែរ"[30]។

---

[29] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌទី៣៦ និងទី៣៨។

[30] Rob Savage, *Monthly South Eastern Globe,* "បាក់ស្បាតៈ កេរ្តិ៍ដំណែលមួយនៃការឈឺចាប់ និងអំពើហិង្សា (Post Traumatic Stress Disorder: A Legacy of Pain and Violence)", ចុះខែ កក្កដា ឆ្នាំ២០០៧, ទំព័រទី២៤-២៧ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ឧបសម្ព័ន្ធ ក, ឯកសារភ្ជាប់ A 25)។

00323136

C9/4/7



៤០. មហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្ត ឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលគិតចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅតែជាបញ្ហាព្រួយបារម្ភរបស់សង្គមកម្ពុជា និងរបស់មនុស្សជាតិ:

> "រំលឹកឡើងវិញថា ការរំលោភបំពានលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិយ៉ាងធ្ងន់ធ្ងរ ក្នុងរយៈពេលរបបកម្ពុជាប្រជាធិបតេយ្យ គិតចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅតែជាបញ្ហាដែលបង្កឱ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល
>
> [...]
>
> ទទួលស្គាល់ថា ការពិចារណាលើការប្រព្រឹត្តអំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ របស់ចារីប្រព្រឹត្តបទល្មើសម្នាក់ៗ គឺជាធាតុសំខាន់មួយក្នុងចំណោមធាតុសំខាន់ៗ នៃដំណោះស្រាយដ៏មានប្រសិទ្ធភាពជូនដល់ជនរងគ្រោះនានា [...]"[31]

៤១. សវនាការនានាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ បានធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្លា ពីសំណាក់ប្រជាជនកម្ពុជានិងអ្នកសារព័ត៌មានកម្ពុជា ក៏ដូចជាសហគមន៍អន្តរជាតិផងដែរ។ ប្រជាជនរាប់រយនាក់ រួមទាំងបុគ្គលិកសាធារណៈ ព្រមទាំងតំណាងអ្នកសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ បានមកចូលរួមស្ដាប់សវនាការទាំងនេះផងដែរ។ ចំណាប់អារម្មណ៍នេះបានចង្អុលបង្ហាញថា ទោះជានៅក្នុងដំណាក់កាលនៃសវនាការបឋមក៏ដោយ ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភយ៉ាងធំធេងដល់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិនាពេលបច្ចុប្បន្ននេះ។

---

[31] *សេចក្ដីសម្រេចអនុម័តដោយមហាសន្និបាត - តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម*, GA Res A/RES/57/228, ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣, បុព្វកថា។

00323137

C9/4/7



៤២. អង្គបុរេជំនុំជម្រះយល់ឃើញថា ការគម្រាមកំហែងសន្តិសុខមិនមែនជាបញ្ហាដែលយើងមិនដឹងនោះទេ។ ទីមួយ បញ្ហានេះត្រូវបានបង្ហាញតាមរយៈការរំខានរាល់ថ្ងៃ ឬក៏ឧក្រិដ្ឋកម្មហឹង្សានានា ដែលធ្វើឲ្យអង្គបុរេជំនុំជម្រះកត់សម្គាល់ថា វាជាការពិតដែលអ្នកណាក៏ដឹងដែរ។ ទីពីរ គំរូនៃការធ្វើកុបកម្មប្រឆាំងនឹងប្រជាជនថៃ នៅឆ្នាំ២០០៣ បញ្ជាក់ឲ្យឃើញថាអាចមានអស្ថេរភាព ដែលបង្កឡើងដោយហេតុផលនយោបាយ[32]។

៤៣. អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គហេតុនានាដែលបានលើកឡើងខាងលើ ពិតជាបង្ហាញថា ការដោះលែងជនត្រូវចោទ នឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈយ៉ាងប្រាកដ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន នៅតែជាវិធានការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

---

[32] John Aglionby, The Guardian, "ប្រជាជនថៃកាត់ផ្តាច់ទំនាក់ទំនងជាមួយប្រទេសកម្ពុជាបន្ទាប់ពីមានកុបកម្ម កើតឡើង" ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៣ (ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ ក១៥)។ សារព័ត៌មាន BBC "អ្នកការទូតថៃបានវិលត្រលប់មកប្រទេសកម្ពុជា" ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ (ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ ក១៦)។ CNN.com "ប្រទេសកម្ពុជាសុំអភ័យទោសចំពោះបញ្ហាកុបកម្ម" ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ (ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ ក១៧)។ Michael Flint ការវាយតម្លៃកម្មវិធីប្រចាំប្រទេស DFID ការសិក្សាអំពីប្រទេសកម្ពុជាពីឆ្នាំ១៩៩៧-២០០៣ ទំព័រទី៤ ((ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះ បណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ ក១៩)។ អង្គការឃ្លាំមើលសិទ្ធិមនុស្សនិងលើកលែងទោសអន្តរជាតិ "ប្រទេសកម្ពុជាៈ សេរីភាពក្នុងការបញ្ចេញមតិក្រោមការវាយប្រហារ" ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ((ចម្លើយតប របស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការ ឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ ក២០)។ ក្រសួងការបរទេស សហរដ្ឋអាមេរិក ការិយាល័យកិច្ចការអាស៊ីបូព៌ានិងប៉ាស៊ីហ្វិក របាយការណ៍ជូនទៅសមាជស្តីពីកុបកម្មប្រឆាំងថៃនៅក្នុង ប្រទេសកម្ពុជា កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ និងទី១៤ ខែឧសភា ឆ្នាំ២០០៣ (ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឧបសម្ព័ន្ធ ក ឯកសារភ្ជាប់ ក២៦)

**ភាពសមហេតុផលនៃរយៈពេលឃុំខ្លួនបណ្ដោះអាសន្ននិងការវិវឌ្ឍនៃការស៊ើបអង្កេត**

៤៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការទាក់ទងគ្នារវាងរយៈពេលដែលជនត្រូវចោទនៅក្នុងមន្ទីរឃុំឃាំង និងការយកចិត្តទុកដាក់ក្នុងការដឹកនាំការស៊ើបអង្កេតគឺជាកត្តាដែលពាក់ព័ន្ធគ្នា នៅពេលពិចារណាបន្តការឃុំខ្លួន ឬការដោះលែង។

៤៥. វិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញដែលយកមកអនុវត្តចំពោះបញ្ហាដែលពាក់ព័ន្ធនេះ មានការទាក់ទិនទៅនឹងរយៈពេលដែលត្រូវបានអនុញ្ញាតៈ វិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង ចែងថា "ការពន្យារពេល [នៃការឃុំខ្លួនបណ្ដោះអាសន្ន] មិនត្រូវឱ្យលើសពី ២ (ពីរ)ដងឡើយ" និងទាក់ទងទៅនឹងការយកចិត្តទុកដាក់ៈ វិធាន ២១(៤) នៃវិធានផ្ទៃក្នុង ចែងថា "ដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែឈានដល់ទីបញ្ចប់នៅក្នុងអំឡុងពេលមួយដែលសមស្រប"។ "ដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ" រួមបញ្ចូលទាំងការស៊ើបអង្កេតរបស់តុលាការផងដែរ។ ការកំណត់ចំពោះការវិវឌ្ឍ នៃការស៊ើបអង្កេត គឺការចំណាយពេលវេលាមានរយៈពេល "សមស្រប" ចំណែកឯការកំណត់ចំពោះពេលវេលាដែលជនត្រូវចោទស្ថិតក្នុងឃុំខ្លួនបណ្ដោះអាសន្ន គឺជាពេលវេលាដែលមានលក្ខណៈជាក់លាក់ណាស់។ វិធាននានាបានបង្ហាញយ៉ាងច្បាស់អំពីរបៀបនៃការកំណត់ដូច្នេះ ពោលគឺការឃុំខ្លួនជនត្រូវចោទគឺជាទម្រង់នៃការដាក់ទណ្ឌកម្ម ដែលមានផលអាក្រក់ច្រើនជាង ពីព្រោះសិទ្ធិមានសេរីភាពរបស់មនុស្សម្នាក់ដែលនៅតែត្រូវបានសន្មតថាគ្មានទោស នៅតែជាបញ្ហា ចោទនៅឡើយ។ ហេតុដូច្នេះ ការពិចារណា ថាតើអាជ្ញាធរស៊ើបអង្កេតត្រូវអនុវត្តវិធានការអ្វីខ្លះ និងថាតើវិធានការទាំងនោះប៉ះពាល់ដល់ស្ថានភាពរបស់ជនត្រូវចោទក្នុងកម្រិតណានោះ នៅតែជាការចាំបាច់។

៤៦. បទដ្ឋានអន្តរជាតិនិយាយអំពីបញ្ហានេះក្នុងន័យប្រហាក់ប្រហែលគ្នា។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) តម្រូវថា ការស៊ើបអង្កេតនិងការដំណើរការនីតិវិធីត្រូវបានអនុវត្តឱ្យបានឆាប់រហ័ស តាមពេលដែលកំណត់ដោយច្បាប់លក្ខន្តិកៈរបស់តុលាការ។ ដរាបណាកិច្ចដំណើរការនីតិវិធីអនុលោមទៅតាមពេលវេលារបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ លក្ខខណ្ឌតម្រូវឱ្យមានការប្រព្រឹត្តិទៅដោយឆាប់រហ័ស

ត្រូវបានគេចាត់ទុកថាបានបំពេញហើយ[33]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី Lubanga បានកត់សម្គាល់ថា:

> "កថាខណ្ឌទី៤ នៃមាត្រា៦០ នៃច្បាប់លក្ខន្តិកៈបានប្រគល់ភារកិច្ចដល់អង្គបុរេជំនុំជម្រះឱ្យបញ្ជាក់ឱ្យបានច្បាស់លាស់ថា ការឃុំខ្លួនជនណាម្នាក់គឺមិនត្រូវបានពន្យារពេលសម្រាប់រយៈពេលមួយដែលមិនសមស្របនោះទេ ដោយសារតែការពន្យារពេល ដែលមិនអាចលើកលែងឱ្យបានរបស់ព្រះរាជអាជ្ញា។ ការពន្យារពេលនៅក្នុងបរិបទនេះ មានន័យថាជាការខកខានមិនបានអនុវត្តតាមពេលវេលាក្នុងកិច្ចដំណើរការរបស់តុលាការឆ្ពោះទៅមុខនោះទេ ដែលវាជាតម្រូវការឱ្យមានការជំនុំជម្រះដោយយុត្តិធម៌។។ ប្រសិនបើការពន្យារពេលបែបនេះត្រូវគេជូនដំណឹង អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យធ្វើការដោះលែងជននោះដោយមានលក្ខខណ្ឌ ឬដោយឥតលក្ខខណ្ឌ"[34]។

៤៧. សេចក្តីណែនាំអាចរកបាននៅក្នុងការអនុវត្តរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលបានកំណត់បទដ្ឋាននៃ "ការយកចិត្តទុកដាក់យ៉ាងពិសេស" របស់អាជ្ញាធរជាតិនៅពេលធ្វើការស៊ើបអង្កេត[35]។ នៅពេលដែលតុលាការយល់ឃើញថាមូលដ្ឋានដែលផ្តល់ដោយអាជ្ញាធរតុលាការជាតិ មានយុត្តិកម្មលើការឃុំខ្លួនបន្ត តុលាការនឹងស្រាវជ្រាវរកឱ្យឃើញថា អាជ្ញាធរជាតិបានយកចិត្តទុកដាក់ក្នុងការដឹកនាំដំណើរការនីតិវិធីរបស់ខ្លួន។

---

[33] ព្រះរាជអាជ្ញា ទល់នឹង Germain Katanga និង Mathieu Ngudjolo Chui, ICC-01/04-01/07 "ការពិនិត្យ "សេចក្តីសម្រេចលើពាក្យសុំដោះលែងនៅក្នុងរយៈពេលចន្លោះមួយរបស់ Mathieu Ngudjolo Chui"" អង្គបុរេជំនុំជម្រះ I ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ទំព័រទី១២។ សូមមើលផងដែរ ព្រះរាជអាជ្ញា ទល់នឹង Thomas Lubanga Dyilo, ICC-01/04-01/06 "ការពិនិត្យ "សេចក្តីសម្រេចលើពាក្យសុំដោះលែងនៅក្នុងរយៈពេលចន្លោះមួយរបស់ Thomas Lubanga Dyilo"" អង្គបុរេជំនុំជម្រះ I ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ ទំព័រទី៦ និង៧។

[34] ព្រះរាជអាជ្ញា ទល់នឹង Germain Katanga និង Mathieu Ngudjolo Chui, ICC-01/04-01/07 OA 4 "សាលដីកានៅក្នុងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដោយ Mathieu Ngudjolo Chui ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I លើពាក្យសុំដោះលែងនៅក្នុងរយៈពេលចន្លោះមួយ" ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ ១៤។

[35] ECHR, Ilijkov v. Bulgaria ពាក្យសុំ លេខ ៣៣៩៧៧/៩៦ "សាលដីកា" ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ៧៧។ សូមមើលផងដែរ Labita v. Italy ពាក្យសុំ លេខ ២៦៧៧២/៩៥ "សាលដីកា" ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០០ កថាខណ្ឌ១៥២ និង ១៥៣។ Assenov និងអ្នកដទៃទៀត v. Bulgaria ពាក្យសុំ លេខ ១៦០២/៦២ "សាលដីកា" ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៨។ និង Wemhoff v. Germany ពាក្យសុំ លេខ ២១២២/៦៤ "សាលដីកា" ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨។

00323140



៤៨. អង្គបុរេជំនុំជម្រះយល់ឃើញថា មានភស្តុតាងនៅក្នុងសំណុំរឿងនេះ ដែលចង្អុលបង្ហាញថា ការស៊ើបអង្កេតមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងរយៈពេលសម្រាប់ការពិចារណា។ ភស្តុតាងថ្មីត្រូវបានបញ្ជូនពីសំណុំរឿងលេខ ០០១ ទៅសំណុំរឿងលេខ ០០២ ដែលបន្ថែមនូវហេតុផលមានសំអាងហេតុនានា ដែលមានពីមុនដែលនាំឲ្យជឿបានថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ចម្លើយរបស់សាក្សីមួយចំនួនដែលបានទទួលរួចមកហើយ និងដីកាចាត់ឲ្យស៊ើបសួរជំនួសដែលនឹងត្រូវចាត់ការ បង្ហាញថាសកម្មភាពស៊ើបអង្កេតនៅក្នុងរយៈពេលសម្រាប់ការពិចារណានេះ បានធ្វើច្រើនរួចមកហើយ។ ការស៊ើបអង្កេតនៅក្នុងរឿងក្តីនេះ ដោយអាជ្ញាធរស៊ើបអង្កេតបានបំពេញលក្ខខណ្ឌ នៃការស៊ើបអង្កេតដោយយកចិត្តទុកដាក់។

៤៩. អង្គបុរេជំនុំជម្រះយល់ឃើញថែមទៀតថា ស្ថានទម្ងន់និងចរិតលក្ខណៈនៃឧក្រិដ្ឋកម្មនានា ដែលជនត្រូវចោទបានរងនូវការចោទប្រកាន់នោះ តម្រូវឲ្យធ្វើការស៊ើបអង្កេតជាទ្រង់ទ្រាយធំ ហើយបើតាមវិសាលភាពនិងការរីកចម្រើននៃការស៊ើបអង្កេតនាពេលបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេតបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនចេញដីកាសម្រេចអំពីការបន្តថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នប្រកបដោយហេតុផល។

## VIII. ការពិចារណាថាតើជម្រើសនៃការដោះលែងមានលក្ខណៈសមស្របដែរឬទេ

៥០. សហមេធាវីការពារក្តីបានអះអាងថែមទៀតនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាលើជម្រើសផ្សេងក្រៅពីការឃុំខ្លួននោះឡើយ។ សហមេធាវីការពារក្តីបានស្នើថា "ការដោះលែងជាបណ្តោះអាសន្ន" ដោយមានភ្ជាប់លក្ខខណ្ឌនានា មានលក្ខណៈសមស្របតាមកាលៈទេសៈទាំងនេះ"[36]។ ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីការពារក្តីមិនបានផ្តល់ភស្តុតាងណាមួយបញ្ជាក់ថា មានការប្រែប្រួលកាលៈទេសៈ ដោយរូបភាពណាមួយនោះទេ។

---

[36] សារណាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១។

00323141



៥១. សហព្រះរាជអាជ្ញាបានស្នើសុំអង្គបុរេជំនុំជម្រះ ឱ្យបដិសេធចោលសំណើសុំឱ្យមានការឃុំខ្លួននៅក្នុងផ្ទះ ឬសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

៥២. អង្គបុរេជំនុំជម្រះបានសម្រេចកាលពីមុនថា "វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញមិនបានកំណត់ឱ្យបានច្បាស់លាស់អំពីជម្រើសផ្សេងៗ នៃការឃុំខ្លួននោះទេ"[37]។ អង្គបុរេជំនុំជម្រះត្រូវតែកំណត់បញ្ហានេះទៅតាមទំហំនៃពាក្យបណ្តឹងឧទ្ធរណ៍ និងមិនត្រូវពិចារណាថា ការដោះលែងជនត្រូវចោទគឺជាការអនុវត្តមួយដាច់ដោយឡែកនោះឡើយ ដូចដែលសហមេធាវីការពារក្តីបានលើកឡើងពីដំបូងនូវសំណើរបស់ខ្លួនសុំឱ្យមានការដោះលែង ដែលជាការប្រឆាំងជំទាស់ទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត ដែលសម្រេចបន្តថិរវេលានៃការឃុំខ្លួននោះ។ នីតិវិធីនេះបានកំណត់ដោយវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង។ យោងតាមវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង ភាគីតែមួយគត់ដែលអាចផ្តល់មតិយោបល់លើបញ្ហានេះ គឺមេធាវីការពារក្តី។ វិធាន ៦៤ នៃវិធានផ្ទៃក្នុងបានផ្តល់ឱ្យមេធាវីការពារក្តីយ៉ាងជាក់លាក់នូវសិទ្ធិសុំឱ្យមានការដោះលែង និងបានផ្តល់ឱ្យព្រះរាជអាជ្ញានូវសិទ្ធិផ្តល់មតិយោបល់ពាក់ព័ន្ធនឹងការស្នើសុំនេះ ប៉ុន្តែវាមិនដូច្នេះទេ នៅពេលដែលនីតិវិធីនៃវិធាន ៦៣(៧) ត្រូវយកមកអនុវត្តនោះ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបានពិចារណាលើសំណើសុំឱ្យមានការដោះលែង ដូចដែលបានលើកឡើងដោយសហមេធាវីការពារក្តី ដែលជាការប្រឆាំងជំទាស់ដោយអនុលោមតាមវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងនោះ សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការផ្តល់មតិយោបល់លើសំណើសុំនេះ ពិតជាត្រូវបានរំលោភបំពានរួចបាត់ទៅហើយ។

៥៣. យោងតាមសារណារបស់មេធាវីការពារក្តី សំណើរបស់គាត់សុំដោះលែង ដោយសំអាងថា ពុំមានមូលដ្ឋានណាមួយ ដើម្បីពិចារណាឱ្យឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ ដូចដែលបានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងនោះទេ។ សំណើនេះត្រូវបានបដិសេធ។ យោងតាមហេតុផលខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានជាច្រើននៅតែត្រូវបានបំពេញ ហើយមូលដ្ឋាននីមួយៗមានហេតុផលគ្រប់គ្រាន់ ដែលអាចបង្គាប់ឱ្យមានការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

[37] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី ១១៥។

៥៤. សំណើសុំឱ្យមានការដោះលែងជនត្រូវចោទដោយមានលក្ខខណ្ឌមួយចំនួន មានន័យថាជាសំណើសុំចេញដីកាឱ្យជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចដែលមានចែងនៅក្នុងវិធាន៦៥ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្ដីមិនបានដាក់អ្វីដែលថ្មី នៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបន្តថិរវេលានៃការឃុំខ្លួននោះទេ។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេតគួរតែបានលើកឡើងនូវអង្គហេតុដែលថា ពុំមានកាលៈទេសៈថ្មីត្រូវបានលើកឡើងនោះទេ ហើយការលើកឡើងបែបនេះគឺជាហេតុផលគ្រប់គ្រាន់ក្នុងការបដិសេធចោលសំណើសុំនេះ។ ពាក់ព័ន្ធនឹងបញ្ហានេះដីការបស់សហចៅក្រមស៊ើបអង្កេតពុំមានហេតុផលគ្រប់គ្រាន់ ហើយហេតុផលដូចដែលបានលើកឡើងពីមុន នឹងត្រូវបានដាក់ជំនួសទៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន។ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ សំណើសុំនេះត្រូវបានបដិសេធចោលដោយមានហេតុផលដូចគ្នា។

## IX. **សេចក្ដីសន្និដ្ឋាន**

៥៥. ដោយពិចារណាលើអង្គហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះយល់ឃើញថា ដីការបស់សហចៅក្រមស៊ើបអង្កេតមានហេតុផលគ្រប់គ្រាន់ ចំពោះអង្គហេតុដែលថា លក្ខខណ្ឌដែលកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៅតែត្រូវបានបំពេញ។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលនេះលក្ខខណ្ឌនេះនៅតែត្រូវបានបំពេញ។

៥៦. អង្គបុរេជំនុំជម្រះបានពិនិត្យដោយខ្លួនឯងផ្ទាល់ទៅលើលក្ខខណ្ឌនៃវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង និងយល់ឃើញថា វិធានការនៃការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន នៅតែជាវិធានការចាំបាច់ ដោយឈរលើមូលដ្ឋានដូចខាងក្រោម: i) ដើម្បីរារាំងជនត្រូវចោទ មិនឱ្យដាក់ការគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បី ii)ថែរក្សាភស្តុតាង ឬការពារមិនឱ្យមានការបំផ្លាញភស្តុតាង iii) ធានាឱ្យមានវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី iv) ការពារសន្តិសុខឱ្យជនត្រូវចោទ v) រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

៥៧. ដោយសារតែដីការបស់សហចៅក្រមស៊ើបអង្កេត ពុំមានហេតុផលគ្រប់គ្រាន់ទៅលើផ្នែកនេះ នៃសេចក្តីសម្រេច ហេតុផលរបស់អង្គបុរេជំនុំជម្រះនឹងត្រូវបានដាក់ជំនួសឱ្យហេតុផលរបស់សហចៅក្រមស៊ើបអង្កេត ដែលមាននៅក្នុងដីកានោះ។

៥៨. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តយ៉ាងត្រឹមត្រូវនូវឆន្ទានុសិទ្ធិក្នុងការចេញដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ អាស្រ័យហេតុនេះ បណ្តឹងឧទ្ធរណ៍នឹងត្រូវបានបដិសេធចោល។

៥៩. សំណើសុំឱ្យមានការដោះលែងដោយមានលក្ខខណ្ឌនានានឹងត្រូវបានបដិសេធចោល ហើយហេតុផលរបស់អង្គបុរេជំនុំជម្រះដែលពាក់ព័ន្ធ នឹងត្រូវដាក់ជំនួសឱ្យហេតុផលរបស់សហចៅក្រមស៊ើបអង្កេត។

00323144

C9/4/7

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៣)

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ:**

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់

២. តម្កល់ដីការបស់សហចៅក្រមស៊ើបអង្កេត ហើយមូលហេតុដែលបានបញ្ជាក់ក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយមូលហេតុដែលបានបញ្ជាក់ក្នុងសាលដីកានេះ

៣. បដិសេធចោលសំណើសុំឲ្យមានការដោះលែង (ដោយមានលក្ខខណ្ឌ)

៤. បដិសេធចោលបណ្តឹងឧទ្ធរណ៍។

សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

**ភ្នំពេញ, ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩**

**អង្គបុរេជំនុំជម្រះ**

**Rowan DOWNING** **ន៉ីយ ថុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**